**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ: ១៦៧ ប្រ.ក

រាជធានីភ្នំពេញ. ថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់

## នាយកដ្ឋានគាំពារ និង អភិរក្សសំណង់បុរាណ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់ប្រធាននាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ

**ស ម្រេ ច**

**ប្រការ ១.-**

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ជាអង្គភាពស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ២.-**

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ មានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើបញ្ជី និងចំណាត់ថ្នាក់ប្រាសាទបុរាណ រមណីយដ្ឋានវប្បធម៌ និងសំណង់ផ្សេងៗទៀតដែលមាននៅតាមខេត្ត-ក្រុងនានា ដោយសហការយ៉ាងជិតស្និទជាមួយ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីរៀបចំទុកជាឯកសារ ។

- គ្រប់គ្រង និងសិក្សាស្រាវជ្រាវ ដើម្បីអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ។

- រៀបចំ ស្ថាបនាអភិរក្សដ្ឋាន នៅតាមបណ្តាប្រាសាទ និងរមណីយដ្ឋានវប្បធម៌នានា ដោយមានអភិរក្សករ និងអ្នកជំនាញផ្សេងៗទៀតធ្វើការនៅទីនោះ។

- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ នូវបណ្តាប្រាសាទបុរាណនានា រមណីយដ្ឋានវប្បធម៌ និងសំណង់បុរាណ ដែលទើបរកឃើញថ្មី ពុំទាន់បោះពុម្ពផ្សព្វផ្សាយ។

- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន។

**ប្រការ ៣.-**

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ដឹកនាំដោយ ប្រធាន មួយរូប និងអនុប្រធាន មួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៤.-**

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ មានការិយាល័យ ចំនួន ប្រាំ និងអង្គភាពមូលដ្ឋានមួយ គឺ :

- ការិយាល័យ រដ្ឋបាល និងគណនេយ្យ
- ការិយាល័យ គ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ
- ការិយាល័យ គ្រប់គ្រងរមណីយដ្ឋានវប្បធម៌
- ការិយាល័យ អភិរក្ស និងជួសជុលសំណង់ប្រាសាទបុរាណ
- ការិយាល័យ ស្រាវជ្រាវ និងចងក្រងឯកសារប្រាសាទបុរាណ
- អង្គភាពមូលដ្ឋាន " **អភិរក្សដ្ឋានអង្គរ** " ថ្នាក់ស្មើការិយាល័យ។

ការិយាល័យនីមួយៗមាន ប្រធាន មួយរូប អនុប្រធាន មួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានភារកិច្ច :

**១- <u>ការិយាល័យ រដ្ឋបាល និងគណនេយ្យ</u>**

- គ្រប់គ្រងការងាររដ្ឋបាលទូទៅ
- សរុបលទ្ធផល ការងារធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងគ្រប់គ្រងឯកសារ
- គ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែត និងបណ្តុះបណ្តាលបង្កើនមុខជំនាញ
- ធ្វើផែនការយុទ្ធសាស្ត្រ និងកម្មវិធីការងារ
- គ្រប់គ្រងចំណូល-ចំណាយ បៀវត្សរ៍ពលកម្ម និងកសាងគំរោងថវិកាប្រចាំឆ្នាំ

- គ្រប់គ្រងសំភារៈចលនទ្រព្យ និងអចលនទ្រព្យរបស់រដ្ឋ។

**២- ការិយាល័យ គ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ**

- គ្រប់គ្រង និងធ្វើបញ្ជីសំណង់បុរាណដើម្បីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានច្បាស់លាស់

- ធ្វើបញ្ជីសារពើភណ្ឌប្រាសាទបុរាណដោយកត់ត្រា ហ៊ានលេខ គូរប្លង់ ចុះលេខសំគាល់ប្រាសាទនីមួយៗ ចងក្រងឯកសារតាមលក្ខណៈបច្ចេកទេស។

- គ្រប់គ្រងតំបន់សំណង់បុរាណទម្រង់ដើម នៃសំណង់បុរាណទូទៅ ដែលនៅតាមបណ្តាខេត្ត-ក្រុងនានា ដោយសហការយ៉ាងជិតស្និតជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង តម្កល់ទុក ឯកសារ និងលើកជាវិធានការជូនអាជ្ញាធរ មានសមត្ថកិច្ច។

**៣- ការិយាល័យ គ្រប់គ្រងរមណីយដ្ឋានវប្បធម៌**

- សិក្សាស្រាវជ្រាវ និងគ្រប់គ្រងដើម្បីការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ

- សហការយ៉ាងជិតស្និទជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ដើម្បីធ្វើការស្រាវជ្រាវគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ និងកំនត់តំបន់ការពារតាមច្បាប់ជាធរមាន។

**៤- ការិយាល័យ អភិរក្ស ជួសជុលប្រាសាទ និងសំណង់បុរាណ**

- រៀបចំស្ថាបនាអភិរក្សដ្ឋាន នៅតាមបណ្តាក្រុមប្រាសាទ និងរមណីយដ្ឋានវប្បធម៌នានា ដោយអភិរក្សករ និងអ្នកជំនាញផ្សេងៗទៀតធ្វើការនៅទីនោះ

- ការអភិរក្ស ថែរក្សា រៀបចំ ជួសជុល និងកំនត់តំបន់ការពារប្រាសាទបុរាណ រមណីយដ្ឋានប្រវត្តិសាស្ត្រ។

**៥- ការិយាល័យ ស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិប្រាសាទបុរាណ**

- ការស្រាវជ្រាវចងក្រងបោះពុម្ព និងផ្សព្វផ្សាយឯកសារប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ដែលទាក់ទងទិននិងប្រាសាទសំណង់បុរាណ រមណីយដ្ឋានវប្បធម៌។

**៦- អភិរក្សដ្ឋានអង្គរ**

- ទទួលរក្សា ការពារ អោយបានម៉ឺងម៉ាត់ ជួសជុលរាល់វត្ថុដែលមានស្រាប់ និងបុរាណវត្ថុដែលត្រូវបានបញ្ជូនមករក្សាទុកនៅក្នុងទីតាំងអភិរក្សដ្ឋានអង្គរ។

**ប្រការ ៦.-**

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណជាអង្គភាពអនុវត្តរបបហិរញ្ញវត្ថុរដ្ឋបាលសាធារណៈ។

**ប្រការ ៧.-**

ប្រការទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនិងប្រកាសនេះ ចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អធិការ នៃអធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធាននាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃព្រះហស្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

អ៊ឹម ឆែម

<u>**ចម្លងជូន**</u> **:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  " ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៨ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃប្រកាសលេខ ១៦៧ប្រក ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ២០០៧

## អង្គការលេខរបស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ

